ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការដឹកនាំ
ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## សិក្ខាសាលាថ្នាក់តំបន់
## ផ្សព្វផ្សាយកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ២០១៤-២០១៨

# កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

រាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៥

# មាតិកា

១. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាអ្វី?

២. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានធ្វើអ្វីខ្លះ?

៣. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនឹងធ្វើអ្វីទៀត?

៤. ទំនាក់ទំនងជាមួយនឹងបណ្តាកំណែទម្រង់របស់រាជរដ្ឋាភិបាល

៥. សន្និដ្ឋាន

# ១. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាអ្វី?

# ១. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ: ជាអ្វី?

## ចំណុចសំខាន់ៗដែលគួរយល់ដឹង



### ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

គឺជាប្រព័ន្ធគ្រប់គ្រងដែលធានាឱ្យថវិកាអាចវិភាជ និងប្រើប្រាស់ ប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព ។



### ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

គឺជាការកែលម្អប្រព័ន្ធគ្រប់គ្រងទាំងមូលជាជំហានៗ ពីការផ្តោតការត្រួតពិនិត្យលើធាតុចូលនិងមជ្ឈការ ទៅការតាមដាន និងវាយតម្លៃលើលទ្ធផលនិងវិមជ្ឈការ ។

### កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

គឺជាកម្មវិធីរបស់រាជរដ្ឋាភិបាល ដែលជោគជ័យរបស់កំណែទម្រង់នេះ អាស្រ័យលើស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃការអនុវត្តប្រកបដោយជោគជ័យរបស់គ្រប់ក្រសួង- ស្ថាប័នទាំងអស់។

# ២. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានធ្វើអ្វីខ្លះ?

# ២. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានធ្វើអ្វីខ្លះ?

## លទ្ធផលសម្រេចបាន

**ភាពជឿទុកចិត្តបាននៃថវិកា (២០០៥-២០០៨)**

**គណនេយ្យភាពហិរញ្ញវត្ថុ (២០០៩-២០១៥)**

**ការផ្សារភ្ជាប់ថវិកានឹងគោលនយោបាយ (២០០៨-២០២០)**

ការប្រមូលចំណូល និងការគ្រប់គ្រងចំណាយត្រូវបានពង្រឹង
លំហូរចំណូល និងការទូទាត់រលូនជាងមុន
(ភាពអាចជឿជាក់បាន)

ការកត់ត្រា និងការធ្វើរបាយការណ៍ហិរញ្ញវត្ថុ បាន និងកំពុងត្រូវបានពង្រឹងនូវភាពត្រឹមត្រូវ ច្បាស់លាស់ ទាន់ពេលវេលា និងភាពសុក្រឹត្យ (ការបង្កើនគណនេយ្យភាព និងតម្លាភាពព័ត៌មានហិរញ្ញវត្ថុ)

ការអនុវត្តផែនការយុទ្ធសាស្រ្តថវិកា ,ថវិកាកម្មវិធី និងអង្គភាពថវិកា បាន និងកំពុងបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយព្រមទាំង ជាមូលដ្ឋានសម្រាប់ការវិភាជ និងប្រើប្រាស់ថវិកា កាន់តែមានស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព

# ៣. កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនឹងធ្វើអ្វីទៀត?

# ៣ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនឹងបានធ្វើអ្វីទៀត?

## ផែនការសកម្មភាព ២០១៥-២០២៥

### ២០១៥

បញ្ចប់ដំណាក់កាលទី២ ដោយសម្រេចឱ្យបានជាសារវ័ន្ត នូវ**គណនេយ្យភាពហិរញ្ញវត្ថុ** និងបន្តពង្រឹងនិងពង្រីក **ការផ្សារភ្ជាប់ថវិកានឹងគោលនយោបាយ**, មាតិកាថវិកាថ្មី, ប្លង់គណនីថ្មី, នីតិវិធីអនុវត្តថវិកាកម្មវិធី, ប្រព័ន្ធព័ត៌មានវិទ្យា និង ពង្រឹងនិងពង្រីកការអនុវត្តផែនការយុទ្ធសាស្រ្តថវិកា,ថវិកាកម្មវិធី និង អង្គភាពថវិកា ព្រមទាំងការអនុវត្តយុទ្ធសាស្រ្តកៀរគរចំណូលរយៈពេលមធ្យម និងពង្រឹងសុក្រឹត្យភាពនៃការព្យាករ និងការធ្វើផែនការ

### ២០១៦-២០២០

ចាប់ផ្តើមដំណាក់កាលទី៣ ដោយផ្តោតលើ**ការកសាងប្រព័ន្ធថវិកាផ្តោតលើលទ្ធផល និងវិមជ្ឈការ** ឱ្យបានពេញលេញ និងចាប់ផ្តើមសាកល្បងប្រព័ន្ធគ្រប់គ្រងដោយសមិទ្ធកម្ម ជាបណ្តើរៗ

### ២០២១-២០២៥

ចាប់ផ្តើមដំណាក់កាលទី ៤ គឺ **គណនេយ្យភាពសមិទ្ធកម្ម** ដោយផ្តោតលើការកសាង ប្រព័ន្ធគ្រប់គ្រងដោយសមិទ្ធកម្មពេញលេញ

# ៤. ទំនាក់ទំនងជាមួយនឹងបណ្ដាកំណែទម្រង់របស់រាជរដ្ឋាភិបាល

## ៤. ទំនាក់ទំនងជាមួយនឹងបណ្ដាកំណែទម្រង់របស់រាជរដ្ឋាភិបាល




PFM : ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

PAR : កំណែទម្រង់រដ្ឋបាលសាធារណៈ

D&D : កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# ៤. ទំនាក់ទំនងជាមួយនឹងបណ្តាកំណែទម្រង់របស់រាជរដ្ឋាភិបាល

- **ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាប្រព័ន្ធគ្រប់គ្រងរបស់រាជរដ្ឋាភិបាលទាំងមូល** ដូច្នេះការកែលម្អប្រព័ន្ធនេះ អាចនឹងតម្រូវឱ្យកែលម្អយន្តការ និងក្របខ័ណ្ឌគតិយុត្តិ ព្រមទាំងលើកកម្ពស់សមត្ថភាពស្ថាប័ន ដើម្បីធានាដល់ការអនុវត្តប្រព័ន្ធថ្មីប្រកបដោយស័ក្តិសិទ្ធភាព ប្រសិទ្ធភាព និងនិរន្តរភាព ។
- **រាល់ការកែទម្រង់ ពិសេសការកែទម្រង់ដែលមានលក្ខណៈជាប្រព័ន្ធ** ត្រូវតែធានា មិនត្រឹមតែទិសដៅស្របគ្នានោះទេ តែក្នុងល្បឿនដូចគ្នាទៀត ទើបអាចធានាការបំពេញឱ្យគ្នាបាន ។ ដូច្នេះគណៈកម្មាធិការ ត្រូវធានាសង្គតិភាពនៃប្រព័ន្ធ, យន្តការ និងក្របខ័ណ្ឌគតិយុត្តិ ព្រមទាំងទិសដៅស្របគ្នា និងល្បឿនដូចគ្នា នៃប្រព័ន្ធនីមួយៗ ឱ្យស្ថិតក្នុងសម្បុកប្រព័ន្ធរួមតែមួយ ។
- **ភាពជាម្ចាស់ និងការទទួលខុសត្រូវផ្ទាល់ របស់ក្រសួងស្ថាប័ននីមួយៗ គឺជាកត្តាសំខាន់និងចាំបាច់បំផុត** ក្នុងការធានាដល់ការអនុវត្តប្រព័ន្ធថ្មីប្រកបដោយស័ក្តិសិទ្ធភាព ប្រសិទ្ធភាព និងនិរន្តភាព គឺមិនមែនគណៈកម្មាធិការទេ ។

# ៤. ទំនាក់ទំនងជាមួយនឹងបណ្ដាកំណែទម្រង់របស់រាជរដ្ឋាភិបាល




ការកែលម្អ ប្រព័ន្ធនេះ អាចនឹង
តម្រូវឱ្យកែលម្អ **យន្តការ** និង
**ក្របខ័ណ្ឌគតិយុត្តិ** ព្រមទាំង
**លើកកម្ពស់សមត្ថភាពស្ថាប័ន**
ដើម្បីធានាដល់ការអនុវត្តប្រព័ន្ធថ្មី
ប្រកបដោយស័ក្តិសិទ្ធភាព
ប្រសិទ្ធភាព និងនិរន្តរភាព។

# ប្រព័ន្ធរួមតែមួយ ?

| PFM | PAR | D&D | ... |
|---|---|---|---|
| -ប្រព័ន្ធ | -ប្រព័ន្ធ | -ប្រព័ន្ធ | -ប្រព័ន្ធ |
| -យន្តការ | -យន្តការ | -យន្តការ | -យន្តការ |
| -ក្របខ័ណ្ឌគតិយុត្តិ | -ក្របខ័ណ្ឌគតិយុត្តិ | -ក្របខ័ណ្ឌគតិយុត្តិ | -ក្របខ័ណ្ឌគតិយុត្តិ |

ដូច្នេះគណៈកម្មាធិការ ត្រូវធានាសង្គតិភាពនៃ **ប្រព័ន្ធ** **យន្តការ** និង **ក្របខ័ណ្ឌគតិយុត្តិ** ព្រមទាំងទិសដៅស្របគ្នា និងល្បឿនដូចគ្នានៃប្រព័ន្ធ នីមួយៗ ឱ្យស្ថិតក្នុងសម្បុកប្រព័ន្ធរួមតែមួយ



# រចនាសម្ព័ន្ធសម្របសម្រួល

សេចក្តីសម្រេចរួមលេខ ០០៦ សហវ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ ២០១៥ ស្តីពីការបង្កើតយន្តការសម្របសម្រួលរវាង D&D, PFM និង PAR

- យន្តការខាងលើនេះ មានភារកិច្ចសម្របសម្រួលកម្រិតនយោបាយ
- ក្នុងកម្រិតបច្ចេកទេស ក្រសួង ស្ថាប័នត្រូវរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តរវាង D&D, PFM, (PAR???) ដែលមានលក្ខណៈបំពេញឱ្យគ្នាទៅវិញទៅមក
- តើ PAR តម្រូវឱ្យក្រសួង ស្ថាប័ន រៀបចំផែនការសកម្មភាព ដែរឬទេ?

# ៥. សន្និដ្ឋាន

# ៥. សន្និដ្ឋាន

- កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមាន **ទិសដៅ យុទ្ធសាស្រ្ត ផែនការសកម្មភាព និងយន្តការអនុវត្តច្បាស់លាស់** ដែលធ្វើឱ្យសម្រេចបានលទ្ធផលគួរជាទីមោទនៈ ។
- **កត្តាកំណត់ជោគជ័យ ជាពិសេសចាប់ពីពេលនេះតទៅ គឺស្ថិតនៅលើក្រសួងស្ថាប័ន** ។ ជាបណ្តើរៗយើង បាន និងកំពុងកសាងប្រព័ន្ធថ្មីដោយកែលម្អលើប្រព័ន្ធបច្ចុប្បន្នជាជំហានៗ ជាមួយនឹងការកែលម្អយន្តការ និងក្របខ័ណ្ឌគតិយុត្តិ ព្រមទាំងផ្តល់ជំនួយបច្ចេកទេស និងការបណ្តុះបណ្តាលសមស្រប ដើម្បីក្រសួងស្ថាប័នអាចចាប់ផ្តើមអនុវត្តប្រព័ន្ធថ្មីបាន។ រីឯការធានាស័ក្តិសិទ្ធភាព ប្រសិទ្ធភាព និងនិរន្តភាពនៃការអនុវត្តប្រព័ន្ធថ្មីនេះ គឺត្រូវពឹងផ្អែកលើក្រសួងស្ថាប័ននីមួយៗទាំងស្រុង ។
- **មានយន្តការនិងមានការយល់គ្នាថា ត្រូវផ្សារភ្ជាប់រវាងកំណែទម្រង់នីមួយៗ ជាពិសេសកំណែទម្រង់ដែលមានលក្ខណៈជាប្រព័ន្ធ** ហើយបាននិងកំពុងពិភាក្សាយ៉ាងសកម្ម ប៉ុន្តែស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព គឺនៅត្រូវបន្តតាមដានបន្តទៀតទើបអាចវាយតម្លៃបាន ។

# សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់